**<u>សូមគោរពជូន</u>**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
**នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

**<u>កម្មវត្ថុ</u>៖** សូមគោរពផ្ញើជូនសម្តេចនូវ លិខិតសំណូមពរឲ្យលុបចោលគំរោង<u>ទំនប់ដនសាហុង</u> និងផ្អាកលើការសម្រេចចិត្តលើគំរោង<u>ទំនប់តាមដងទន្លេមេ</u>នៃទន្លេមេគង្គ ។

យើងខ្ញុំទាំងអស់គ្នាជា **សម្ព័ន្ធទន្លេកម្ពុជា** បានឯកភាពគ្នាក្នុងការផ្ញើលិខិតជូនសម្តេចដើម្បី សម្តែងនូវការព្រួយបារម្ភរបស់យើងខ្ញុំអំពីការសាងសង់ **ទំនប់ដនសាហុង** ដែលមានទីតាំងស្ថិតនៅក្នុងល្បាក់ខោន មានចំងាយតិចជាង២គីឡូម៉ែត្រពីព្រំប្រទល់កម្ពុជា-ឡាវ។ ប្រសិនបើមានការសាងសង់ទំនប់ដនសាហុង នឹងមានការបង្កើតជារនាំងឆ្លងកាត់ព្រែកហូសាហុង ជាព្រែកមួយដែលទទួលស្គាល់ដោយអ្នកជំនាញលើវិស័យជលផលថាជាព្រែកដែលសំខាន់នៅក្នុងល្បាក់ខោន ថាជាកន្លែងដែលធនធានជលផលឆ្លងកាត់ពេញមួយឆ្នាំ(ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ របស់គណៈកម្មការទន្លេមេគង្គ ទំព័រ ៣១ និង៩៤)។ ការបម្លាស់ទីរបស់ត្រីដោយឆ្លងកាត់ល្បាក់ខោន គឺជាដំណាក់កាលសំខាន់នៃវដ្តជីវិតរបស់ប្រភេទត្រីជាច្រើននៅទន្លេមេគង្គ ហើយការសាងសង់ទំនប់កាត់ព្រែកហូសាហុង នឹងផ្តល់ផលប៉ះពាល់អវិជ្ជមានយ៉ាងធ្ងន់ធ្ងរដល់ការបន្តពូជរបស់ជលផលទឹកសាប ដែលជាធនធានដ៏មានសារៈសំខាន់សំរាប់វិស័យសេដ្ឋកិច្ចកម្ពុជា និងការចិញ្ចឹមជីវិតរបស់ប្រជាជនកម្ពុជា។

ការសិក្សាថ្មីៗរបស់ វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍធនធានជលផលទឹកសាប (នាយកដ្ឋានជលផល នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ) បានលើកឡើងអំពីការផ្លាស់ប្តូរនូវបរិមាណធនធានជលផលទឹកសាប ដែលនឹងអាចធ្វើឲ្យមានផលប៉ះពាល់អវិជ្ជមានយ៉ាងខ្លាំងទៅលើសន្តិសុខស្បៀង និងអាហាររូបត្ថម្ភ និងសុខភាពសាធារណៈ ដែលនឹងបណ្តាលឲ្យមានការលំបាកក្នុងការចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋខ្មែរ ដែលផ្ទុយពីការប្តេជ្ញាចិត្តក្នុងការសម្រេចឲ្យបាននូវទិសដៅអភិវឌ្ឍន៍សហសវត្សរបស់កម្ពុជា។

យើងមានការព្រួយបារម្ភយ៉ាងខ្លាំង អំពីរបាយការណ៍សិក្សាជាបន្តបន្ទាប់ស្តីពីផលប៉ះពាល់នៅប្រទេសកម្ពុជា ដែលអះអាងថាទំនប់នឹងមិនផ្តល់ផលប៉ះអ្វីធ្ងន់ធ្ងន់ទៅលើលំហូររបស់ទន្លេមេគង្គ ធនធានជលផល ឬការបំលាស់ទីរបស់ត្រីនោះទេ។ ការវាយតម្លៃនេះមានលក្ខណៈផ្ទុយទៅនឹងការរកឃើញដោយវិទ្យាសាស្ត្រ ដែលបង្ហាញថាមានហានិភ័យធ្ងន់ធ្ងរនឹងបង្កឡើងដោយសារគម្រោងចំពោះវិស័យជលផល និងជីវភាពរបស់ប្រជាជននៅខ្សែទឹកខាងក្រោម រួមទាំងប្រទេសកម្ពុជាផងដែរ។ វិធានការកាត់បន្ថយដែលស្នើដោយអ្នកអភិវឌ្ឍទំនប់មិនធ្លាប់មានការសាកល្បង និងមិនមានការស្រាយបញ្ជាក់ច្បាស់លាស់ និងមិន

អាចប្រើប្រាស់បានដោយជោគជ័យឡើយទោះបីនៅតាមដងទន្លេមេគង្គ ឬក៏ទន្លេតំបន់ត្រូពិចផ្សេងៗក្តី ហើយក៏មានការធានាតិចតួចណាស់ដល់ភាពជោគជ័យក្នុងការអនុវត្ត។

លើសពីនោះទៀត រដ្ឋាភិបាលប្រទេសឡាវក្នុងពេលបច្ចុប្បន្នកំពុងអះអាងថាទំបន់ដនសាហុងមិនស្ថិតលើទន្លេមេគង្គទេ ហេតុដូច្នេះហើយទើបរដ្ឋាភិបាលឡាវបានអនុវត្តត្រឹមតែ ″ការជូនដំណឹងជាមុន″ ប៉ុណ្ណោះ ដោយមិនចាំបាច់ធ្វើការពិគ្រោះយោបល់ជាមួយប្រទេសជិតខាងលើដំណើរការសាងសង់ទេ។ ទំនប់ដនសាហុងគឺជាទំនប់ដែលសង់លើទន្លេមេ ដែលមានផលប៉ះពាល់ឆ្លងដែនយ៉ាងច្បាស់ជាមួយទីតាំងចម្ងាយត្រឹមតែ២គីឡូម៉ែត្រពីព្រំដែនកម្ពុជា-ឡាវប៉ុណ្ណោះ។ ហេតុនេះហើយ ការសាងសង់ទំនប់ដងសាហុងនេះ ត្រូវតែឆ្លងកាត់ ″ការពិគ្រោះយោបល់ជាមុន" សិន ដោយផ្អែកលើនិតិវិធីចំពោះការជូនដំណឹង ការពិគ្រោះយោបល់ជាមុន និងកិច្ចព្រមព្រៀង ដែលមានចែងក្នុងកិច្ចព្រមព្រៀងទន្លេមេគង្គឆ្នាំ១៩៩៥។ នេះផ្អែកលើការអនុលោមតាមការរកឃើញនៃកំណែទម្រង់ឆ្នាំ២០០៧នៃការវាយតម្លៃផលប៉ះពាល់បរិស្ថានលើផែនការសាងទំនប់ដងសាហុងដែលធ្វើឡើងដោយលេខាធិការអនុតំបន់ទន្លេមេគង្គ ដែលបានថ្លែងថាការសាងសង់ត្រូវតែមាន ″ការពិគ្រោះយោបល់ជាមុន″សិន។

មកទល់សព្វថ្ងៃ មិនទាន់មានការបង្ហាញអំពីឆន្ទៈរបស់ប្រទេសឡាវ ក្នុងការពិគ្រោះយោបល់ជាមួយរាជរដ្ឋាភិបាលកម្ពុជា និងប្រជាពលរដ្ឋរងគ្រោះដែលរស់តាមទន្លេមេគង្គនៅកម្ពុជាឡើយ។ ការវាយតម្លៃលើផលប៉ះពាល់ជាបន្តបន្ទាប់បានបង្ហាញថា មិនទាន់មានការពិគ្រោះយោបល់ជាសាធារណៈជាផ្លូវការ រឺការប្រជុំផ្សេងៗណាមួយ ដើម្បីផ្តល់ព័ត៌មានដល់អាជ្ញាធរដែលពាក់ព័ន្ធអំពី ការសាងសង់ទំនប់ដងសាហុងនោះឡើយ។ ដោយសារគម្រោងដងនសាហុង នឹងផ្តល់នូវហានិភ័យដ៏ធ្ងន់ធ្ងរដល់ប្រទេសកម្ពុជា ជាពិសេសសហគមន៍ដែលងាយរងគ្រោះ ដូច្នេះអាជ្ញាធរកម្ពុជា និងអ្នកពាក់ព័ន្ធផ្សេងទៀតនៅកម្ពុជាត្រូវតែមានអន្តរាគមន៍ជាចាំបាច់ក្នុងការធ្វើសេចក្តីសម្រេចលើការអនុវត្តគម្រោងនេះ។ បន្ថែមទៅលើនេះទៀត គួរតម្រូវឲ្យមានការសិក្សាអំពីផលប៉ះពាល់ឲ្យបានស៊ីជម្រៅ និងមានការសិក្សាអំពីផលប៉ះពាល់ឆ្លងដែន ដើម្បីបំពេញភាពខ្វះចន្លោះនៅក្នុងការសិក្សាអំពីផលប៉ះពាល់នៃការសាងសង់ទំនប់ដែលបានសិក្សាកន្លងមក។

ក្រុមអង្គការសង្គមស៊ីវិលយើងខ្ញុំ សូមធ្វើការកោតសរសើរដោយស្មោះចំពោះគណៈកម្មាធិការជាតិទន្លេមេគ្គកម្ពុជាដែលបានអំពាវនាវឲ្យគំរោងទំនប់ដនសាងហុងឲ្យ **ធ្វើការពិគ្រោះយោបល់ជាមុន** មុននឹងធ្វើការសាងសង់ទំនប់។ ហានិភ័យនឹងអាចកើតមានជាច្រើនប្រសិនបើគម្រោងសាងសង់ទំនប់មិនមានការពិចារណាឲ្យបានស៊ីជម្រៅអំពីផលប៉ះពាល់មកលើប្រទេសកម្ពុជា។

ក្រុមអង្គការសង្គមស៊ីវិលយើងខ្ញុំបានទទួលដំណឹងថានឹងមានកិច្ចប្រជុំពិសេសរបស់គណៈកម្មការពិសេសរបស់គណៈ-កម្មការជាតិទន្លេមេគង្គ ដែលនឹងរៀបចំឡើងនៅ ថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៤ នៅទីក្រុងវៀងច័ន្ទ ប្រទេសឡាវ ដើម្បីពិភាក្សាអំពីគំរោងទំនប់ដនសាហុង។ ក្នុងកិច្ចប្រជុំដែលនឹងរៀបចំឡើងនោះ ក្រុមអង្គការសង្គមស៊ីវិលយើងខ្ញុំសូមស្នើដល់រាជដ្ឋាភិបាលកម្ពុជាដូចខាងក្រោម៖

- ជំរុញឲ្យរដ្ឋាភិបាលឡាវធ្វើការពន្យារពេលការសាងសង់គំរោងទំនប់ដនសាហុង និងគោរពទៅតាមកិច្ចព្រមព្រៀងទន្លេមេគង្គ ដោយដាក់សំណើគំរោងទំនប់ដនសាងហុងឲ្យមាន **ការពិគ្រោះយោបល់ជាមុន។**
- ស្នើឲ្យលេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គធ្វើការត្រួតពិនិត្យឡើងវិញដោយភាពឯករាជ្យអំពីគំរោងទំនប់ដនសាហុងមេគង្គ។
- ធានាឲ្យបានថាការវាយតម្លៃផលប៉ះពាល់ឆ្លងដែននឹងត្រូវធ្វើការសិក្សាដែលតម្រូវឲ្យបញ្ចូលទស្សនៈរបស់សហគមន៍ និងអ្នកពាក់ព័ន្ធផ្សេងៗទៀតនៅក្នុងប្រទេសកម្ពុជា។
- ស្នើឲ្យមានការផ្អាកគ្រប់គំរោងទំនប់តាមដងទន្លេមេទាំងអស់ក្នុងខណៈពេលដែលមានការរៀបចំជាវេទិការសំរាប់ការពិភាក្សា ពិនិត្យឡើងវិញ និងដោះស្រាយបញ្ហានៃការអនុវត្តដំណើរការពិគ្រោះយោបល់របស់គណកម្មការទន្លេមេគង្គដើម្បីឈានទៅដល់កិច្ចព្រមព្រៀងរួមគ្នាមួយទៅលើការបកស្រាយតាមរយៈការសម្រេចចិត្តនៅកំរិតតំបន់ដោយផ្អែកលើគោលការណ៍តម្លាភាព និងការចូលរួមពេញលេញរបស់អ្នកពាក់ព័ន្ធទាំងអស់។

ដូចនេះ យើងខ្ញុំ **សម្ព័ន្ធទន្លេកម្ពុជា សូមជំរុញឲ្យ សម្តេច ធ្វើការទាមទារឲ្យលុបចោលនូវគំរោងទំនប់ដនសាហុង និងធ្វើការផ្អាកលើការសម្រេចចិត្តលើគំរោងទំនប់តាមដងទន្លេមេផ្សេងៗទៀត ដើម្បី ផលប្រយោជន៍ដល់ប្រជាជនក្នុងប្រទេសកម្ពុជា និងក្នុងតំបន់ទាំងមូល ។**

សូមសម្តេចទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់បំផុតអំពីយើងខ្ញុំ ។

ធ្វើនៅ រាជធានីភ្នំពេញ ថ្ងៃទី១០ ខែ មករា ឆ្នាំ ២០១៤

**<u>តំណាងសម្ព័ន្ធទន្លេកម្ពុជា៖</u>**

វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា (NGOF)

បណ្តាញការពារទន្លេបី (3SPN)

សម្ព័ន្ធភាពដើម្បីដើម្បីអភិរក្សធនធានជលផល (FACT)

សមាគមថែក្សាបរិស្ថាន និងវប្បធម៌ (CEPA)

អង្គការភូមិខ្ញុំ (MVi)

អង្គការស្ម័គ្រចិត្តដើម្បីសង្គម (CVS)

អង្គការសង្គ្រោះអ្នកងាយរងគ្រោះកម្ពុជា (SVC)

អង្គការអភិវឌ្ឍន៍សេដ្ឋកិច្ចសហគមន៍ (CED)

សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍនៅកម្ពុជា (ADHOC)

សមាគមកសិករខ្មែរ (KFA)

អង្គការអភិវឌ្ឍន៍ជនបទភាគពាយព្យ (NRD)

អង្គការពន្លកខ្មែរ

មជ្ឈមណ្ឌលម្លប់ព្រហ្មវិហារធម៌

អង្គការសហប្រតិបត្តិការបរិស្ថាន និងទេសចរណ៍ (CETO)

មូលនិធិសកលសម្រាប់ការអភិរក្សធម្មជាតិ កម្ពុជា (WWF)

**ចម្លងជូន៖**

- គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា (CNMC)
- អជ្ញាធរទន្លេសាប
- ក្រសួងបរិស្ថាន (MoE)
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (MAFF)
- ក្រសួងរ៉ែ និងថាមពល (MoME)
- ក្រសួងទេសចរណ៍ (MoT)

*ផ្ទះលេខ ៩-១១ ផ្លូវ ៤៧៦ ទួលទំពូង១ ភ្នំពេញ ប្រអប់សំបុត្រលេខ ២២៩៥ ភ្នំពេញ-៣ # 9-11, St476, Toul Tompoung1,Phnom Penh, P.O. Box 2295 Phnom Penh-3 Tel: (855) 23 214 429 Fax: (855) 23 994 063*